ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំឆ្នាំ២០១៤

នៅក្នុងឆ្នាំ២០១៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ៖

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០៥លើក

-អញ្ជើញចូលរួមជាអធិបតីក្នុងពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៣៥ នៃទិវាជ័យជំនះ ៧ មករា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ

-ទទួលជួបបដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិសរុបចំនួន០៥លើក

-បានណែនាំ និងឧបត្ថម្ភដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់សម្តេចឲ្យចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត ក្រុងនានាបានចំនួនសរុប១១លើក និងបានពិនិត្យព្យាបាលប្រជាពលរដ្ឋសរុបចំនួន២៦,៥៩៦នាក់

-អញ្ជើញចេញទៅបរទេសសរុបចំនួន០៣លើក

-បានប្រារព្ធពិធីផ្សេងៗ និងបានចែកអំណោយជូនដល់ប្រជាជនក្រីក្រ សរុបចំនួន ១០លើក

-ចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិជូនឯកឧត្តម **សាយ ឈុំ** អនុប្រធានទី១ព្រឹទ្ធសភា ឲ្យទទួលបន្ទុកដឹកនាំអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២០លិខិត, ប្រជុំវិសាមញ្ញចំនួន០៣លិខិត និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន១០លិខិត

-ចុះហត្ថលេខាលើកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ នៃការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភានីតិកាលទី៣ចំនួន៦២ច្បាប់

-ចុះហត្ថលេខាលើសេចក្តីសម្រេចចំនួន១០ ព្រះរាជក្រមចំនួន០២ ព្រះរាជក្រឹត្យ ចំនួន២២៩ លិខិតស្នើសុំប្រទានសិទ្ធិពីព្រះមហាក្សត្រចំនួន២៣៣លិខិត និងលិខិតផ្សេងៗចំនួន១៦៥លិខិត។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

**១.២ ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ ព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០៩លើក

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២៣លើក កិច្ចប្រជុំពេញអង្គចំនួន១២លើក និងកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចូលរួមកិច្ចប្រជុំថ្នាក់កំពូលរវាងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ស្តីពីដំណោះស្រាយនយោបាយរវាងគណបក្សទាំងពីរ នៅវិមានព្រឹទ្ធសភា

-អញ្ជើញចុះបំពេញការងារនៅមូលដ្ឋានរាជធានី-ខេត្តចំនួន២៩លើក

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងកម្មវិធីផ្សេងៗចំនួន១៥លើក

-អនុញ្ញាតឲ្យគណៈប្រតិភូ និងឯកអគ្គរដ្ឋទូតពីប្រទេសនានា ចូលជួបសវនាការ និងសម្តែងការគួរសមចំនួន០៦លើក៖

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម **ង្វៀង តិនសាង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូជាន់ខ្ពស់ មកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា

-ទទួលជួបសវនាការ និងពិភាក្សាការងារជាមួយគណៈប្រតិភូ ក្រុមប្រឹក្សាសភាសហព័ន្ធនៃសហព័ន្ធរុស្ស៊ី ដឹកនាំដោយឯកឧត្តម Evgeny Serebrennikov អនុប្រធានទី១គណៈកម្មការការពារជាតិ និងសន្តិសុខជាតិ នៃសភាសហព័ន្ធ សហព័ន្ធរុស្ស៊ី

-ទទួលជួបសវនាការ និងពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិសភាប្រឹក្សានយោបាយប្រជាជនចិន ដឹកនាំដោយឯកឧត្តម Chen Xiaoguang អនុប្រធានសភាប្រឹក្សានយោបាយ ប្រជាជនចិន

-ទទួលឯកឧត្តម **Dmitry Tsvetkov** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការ និងសម្តែងការគួរសម

-ទទួលឯកឧត្តម **Joachim Baron Von Marschall** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសវនាការសម្តែងការគួរសម និងពិភាក្សាការងារ

-ទទួលឯកឧត្តម Azuma KOSHIISHI អនុប្រធានព្រឹទ្ធសភាជប៉ុន ចូលជួបសវនាការ និងសម្តែងការគួរសម

-ជ្រាបជាព័ត៌មាន ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៨៦៧ច្បាប់ ។

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន៖**

-អញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១៩លើក ប្រជុំពេញអង្គចំនួន០៩លើក និងអញ្ជើញដឹកនាំ និងចូលរួមប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០៣លើក

-អញ្ជើញចូលរួមប្រជុំរៀបចំក្បាលម៉ាស៊ីនដឹកនាំរបស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសវិមានព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចូលរួមប្រជុំការងារសមាគមន៍មិត្តភាពកម្ពុជា-ចិន ក្រោមអធិបតីភាពឯកឧត្តម **ឯក សំអុល** នៅសាលប្រជុំក្រុមប្រឹក្សារដ្ឋធម្មនុញ្ញចំនួន០២លើក

-អញ្ជើញជួបសំណេះសំណាល និងចែកអំណោយជូនកម្មាំងទាហានជើងទឹក, សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋក្រីក្រ ចាស់ជរា ជនពិការចំនួន០៤លើក

-អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃសុន្ទរកថាបើក និងចូលរួមវេទិកា នៅភូមិភាគ១, ភូមិភាគ២, ភូមិភាគ៣, ភូមិភាគ៤, ភូមិភាគ៥ និងភូមិភាគ៧សរុបចំនួន០៨លើក

-អនុញ្ញាតឲ្យភ្ញៀវជាតិ និងអន្តរជាតិចូលជួបសម្តែងការគួរសម និងពិភាក្សាការងារចំនួន០៥លើក

-អញ្ជើញជាអធិបតី និងជាកិត្តិយសក្នុងអង្គសិក្ខាសាលា សន្និសីទ សន្និបាត និងពិធីផ្លូវការផ្សេងៗចំនួន៣៦លើក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩៣១ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ និងប្រជុំពេញអង្គព្រឹទ្ធសភា**

បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២៣លើក ប្រជុំវិសាមញ្ញចំនួន០៣លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន១៤លើក និងពិនិត្យ ឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន២១ច្បាប់ ដែលព្រឹទ្ធសភាទទួលបានពីរដ្ឋសភា ។

**៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

ក្នុងឆ្នាំ២០១៤នេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

**៣.១ មុខងារនីតិកម្ម**

គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន២១ ។

### ៣.២ មុខងារត្រួតពិនិត្យ

បានជួបសវនាការជាមួយក្រសួងសង្គមកិច្ច រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល និងអគ្គនាយកពន្ធនាគារ ដើម្បីស្វែងយល់ អំពីលទ្ធផលការងារដែលពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ ដែលក្រសួង ស្ថាប័ននានា របស់រដ្ឋាភិបាលនឹងកំពុងអនុវត្ត ។

### ៣.៣ មុខងារតំណាង

-ទទួលពាក្យបណ្តឹងចំនួន៤៥ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន២៦ករណី ទទួលលិខិតឆ្លើយតបអំពីលទ្ធផលនៃដំណោះស្រាយពាក្យបណ្តឹងបានចំនួន១៣ករណី តម្កល់ទុកមិនចាត់ការចំនួន១៩ករណី ធ្វើលិខិតជំរុញការដោះស្រាយបណ្តឹងទៅក្រសួងស្ថាប័នពាក់ព័ន្ធចំនួន០៣ករណី ទទួលពាក្យបណ្តឹង និងឯកសារជូនជ្រាបពីក្រសួងស្ថាប័នពាក់ព័ន្ធបានចំនួន៨០ករណី ។

-សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន ៨៨៧លើក ដើម្បីចុះជួយប្រជាពលរដ្ឋជួបគ្រោះមហន្តរាយខ្យល់ព្យុះ(បាក់ផ្ទះ) ភ្លើងឆេះ(ផ្ទះផ្សារ ) រងគ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួត ជួបពិភាក្សាការងារ សំណេះសំណាលសាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ចែកប័ណ្ណកម្មសិទ្ធដីធ្លី ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិ-ភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗសរុបចំនួន៥៥៦លើក ។

### ៣.៤ មុខងារព័ត៌មាន

-សមាជិក-សមាជិកា គណៈកម្មការនានារបស់ព្រឹទ្ធសភាបានចុះបំពេញបេសកកម្មតាមបណ្តាខេត្តក្រុងចំនួន១៩លើក ដើម្បីស្វែងរកព័ត៌មានអំពីការអនុវត្តច្បាប់ គម្រោងអភិវឌ្ឍនានា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ត្រួតពិនិត្យអំពីស្ថានភាពជម្លោះដីធ្លី បញ្ហាសុខភាពមាតា ទារក ការប្រើប្រាស់ថវិកាថ្នាក់ក្រោមជាតិ អនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងវិស័យផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ ។

## ៤.កិច្ចសហប្រតិបត្តិការអន្តរជាតិ

-សមាជិក-សមាជិកា គណៈកម្មការនានារបស់ព្រឹទ្ធសភា ចំនួន៦៥រូប បានអញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត សន្និសីទ វេទិកា និងពិធីផ្សេងៗ នៅប្រទេសវៀតណាម ឡាវ ថៃ ម៉ាឡេស៊ី ចិន ស្រីលង្កា ជប៉ុន សហរដ្ឋអាមេរិក បារាំង ឥណ្ឌូនេស៊ី ប្រ៊ុយណេ អាល្លឺម៉ង់ កាណាដា ហុងគ្រី ស្វីស ម៉ិកស៊ិក ស៊ុយអ៊ែត សាធារណរដ្ឋអាស៊ែបៃហ្សង់ សាធារណរដ្ឋបេឡារុស្ស សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន និងសាធារណរដ្ឋ អ៊ីស្លាមអ៊ីរ៉ង់ ។ល។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ